# ក្រុមប្រឹក្សាភិបាល

លោក ហៃ ឆេង :
ប្រធានសមាគមខ្មែរ
កញ្ញាបណ្ឌិត ជា ផល្លា :
អនុប្រធានសមាគមខ្មែរ
លោក William Lipchitz : ហិរញ្ញិក
លោក Stuart Santelmann : លេខាធិកា
លោក James J. Cook : សមាជិក
លោក នាង សុវណ្ណារា : សមាជិក
លោក ទូច វ៉ាន់ : សមាជិក
អ្នកនាង ស្ម៊ីង មេឡូឌី : សមាជិក
អ្នកនាង ស្ម៊ីន សុភី : សមាជិក
លោក ម៉ែន បូរ៉ាត់ : សមាជិក

## ក្រុមប្រឹក្សា

វេជ្ជបណ្ឌិត កែវ សម្បត្តិ
លោក ឌឹន វ៉ាសុនា
លោក អ៊ុង ចាន់រិទ្ធី
លោកបណ្ឌិត Jeffery Gerson
លោកមេធាវី អ៊ុន វ៉ានថន
លោកមេធាវី Thomas Stylianos, Jr.

## Mission Statement

The Cambodian Mutual Assistance Association is dedicated to improving the quality of life for Cambodian Americans and other minorities and economically disadvantaged persons in Lowell through educational, cultural, economic and social programs.

*A United Way Impact Partner*

Cambodian Mutual Assistance Association
of Greater Lowell, Inc.
165 Jackson Street
Lowell, MA 01852

**Cambodian Mutual Assistance Association of Greater Lowell, Inc.**

**165 Jackson Street**
**Lowell, MA 01852**
**(978) 596-1000**
**Fax: (978) 454-1806**
**www.cmaalowell.org**

**Vong Ros, Executive Director**
**Hai Cheng, President**



Cambodian Mutual Assistance Association

## សមាគមខ្មែរក្រុងឡូវែល

**165 Jackson Street**
**Lowell, MA 01852**

ជាង២១ឆ្នាំមកនេះសមាគមខ្មែរបានជួយសហគមន៍យើង និងសហគមន៍អាស៊ីអគ្នេយ៍ដទៃទៀតដោយបានផ្តល់សេវាកម្មនិងកម្មវិធីផ្សេងៗ ។ សមាគមខ្មែរជាអង្គការសង្គមមួយដែលផ្តោតទៅលើការផ្តល់កម្មវិធីនិងសេវាកម្មដើម្បីលើកស្ទួយជីវភាពរស់នៅរបស់សហគមន៍ខ្មែរអាមេរិកកាំងប្រចាំក្រុងឡូវែល ។ ជារៀងរាល់ឆ្នាំយើងជួយដល់ជនភៀសខ្លួនខ្មែរនិងជនភៀសខ្លួនអាស៊ីអគ្នេយ៍ដទៃទៀតព្រមទាំងក្រុមគ្រួសាររបស់គេរាប់រយអ្នកឲ្យសំរេចបាននូវសុក្កានុពលសង្គម និងសេដ្ឋកិច្ចរបស់ខ្លួន។



# កម្មវិធី និង សេវាកម្ម

***កម្មវិធីលើកកំពស់សុខភាពសហគមន៍ខ្មែរ*** : កម្មវិធីនេះបង្រៀនអ្នកចូលរួម ឬសិក្ខាកាមឲ្យចេះទំនាក់ទំនងកាន់តែប្រសើរឡើងនិងមានប្រសិទ្ធិភាពជាមួយបណ្តាសេវាសុខភាពផ្សេងៗ ព្រមទាំងផ្តល់ពត៍មានអំពីការព្យាបាលនិងការការពារជម្ងឺមួយចំនួនដូចជា : ជម្ងឺទឹកនោមផ្អែម, ជម្ងឺបេះដូង, ជាតិខ្លាញ់នៅក្នុងសរសៃឈាម, ជម្ងឺឆ្អឹងស្តើង និងជម្ងឺលើសឈាមជាដើម ។ កម្មវិធីនេះផ្តត់ផ្តង់ថវិការដោយការិយាល័យជនភៀសខ្លួន និងការតាំងទីលំនៅជាថ្មីនៃសហរដ្ឋអាមេរិក ។

**កម្មវិធីសុខភាពសហគមន៍ខ្មែរ២០១០** : កម្មវិធីនេះអប់រំប្រជាពលរដ្ឋអំពីបញ្ហាសុខភាព ។ កម្មវិធីនេះមានការរួមសហការណ៍គ្នាយ៉ាងជិតស្និតរវាងមណ្ឌលសុខភាពក្រុងឡូវែល និងបណ្តាភ្នាក់ងារផ្តល់សេវាសុភាពដទៃទៀត ។ វាគឺជាផ្នែកមួយនៃការផ្តួចផ្តើមគំនិតផ្នែកសុខភាពប្រជាពលរដ្ឋឆ្នាំ២០១០របស់មជ្ឈមណ្ឌលបង្ការជម្ងឺសហរដ្ឋអាមេរិក ។ គោលដៅចម្បងនៃកម្មវិធីនេះគឺដើម្បីកាត់បន្ថយកំលាតសុខភាពខាងជម្ងឺបេះដូងរវាងពលរដ្ឋខ្មែរអាមេរិកាំងឬជនភៀសខ្លួនខ្មែរ និងប្រជាពលរដ្ឋទូទៅ ។

***កម្មវិធីមនោរម្យជំនួយគ្រួសារខ្មែរ*** : កម្មវិធីនេះមានតួនាទីបំរើសេចក្តីតូវការគ្រួសារខ្មែរណាដែលកូនមានបញ្ហាផ្នែកសតិ-ប្រាជ្ញា និងមានអាយុចាប់ពី ៣ ដល់ ២២ឆ្នាំ ។ កម្មវិធីមនោរម្យជំនួយគ្រួសារខ្មែរផ្តល់នូវសេវាកម្មដូចជា ៖ ជួយបកប្រែភាសា, ជួយដឹកជញ្ជូនទៅពេទ្យនានា, ដោះស្រាយវិបត្តិផ្សេងៗ, ជួយផ្តល់យោបល់, ជួយចាត់ចែងសំណុំរឿងផ្សេងៗ, ជួយទំនាក់ទំនងខាងការអប់រំពិសេស, ជួយសំរួលសេចក្តីត្រូវការផ្សេងៗនៅតាមផ្ទះ និងធ្វើការបញ្ជូនទៅកាន់ក្រសួងនានាដើម្បីស្វែងរកជំនួយដែលត្រូវការ ។

***កម្មវិធីជួយដល់មាតាបិតាវ័យជំទង់*** : កម្មវិធីនេះផ្តោតទៅលើការកាត់បន្ថយការពឹងអាស្រ័យទាំងស្រុងទៅលើប្រព័ន្ធសុខមាលភាពរដ្ឋរបស់មាតាបិតាដែលមានវ័យក្មេងចាប់ពីអាយុពី១៤ ដល់ ២១ឆ្នាំដែលពុំបានទទួលសញ្ញាប័ត្រវិទ្យាល័យ ឬកម្រិតសិក្សាប្រហាក់ប្រហែលនឹងវិទ្យាល័យ ។ កម្មវិធីនេះអនុវត្តតាមគំរូនៃកម្មវិធីអភិវឌ្ឍន៍ភាពអាចរកការងារបានដើម្បីឲ្យបុគ្គលម្នាក់ៗត្រៀមលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលការងារក្នុងទីផ្សារការងារដំបូងៗយ៉ាងឆាប់បំផុតដែលអាចធ្វើទៅបាន ។ កម្មវិធីមាតាបិតាវ័យជំទង់របស់សមាគមខ្មែរផ្តោតការយកចិត្តទុកដាក់លើបញ្ហាគ្រប់ជ្រុងជ្រោយរបស់មនុស្ស ដោយទទួលស្គាល់ថាការអប់រំជាមូលដ្ឋាននិងការអភិវឌ្ឍន៍ទេព្យ កោសល្យការងារជាកត្តាសំខាន់បំផុតចំពោះមាតាបិតាវ័យជំទង់ក្នុងការរកការងារ និងក្នុងការជំរុញវឌ្ឍនភាពក្នុងការប្រកបការងាររបស់គេ ។ កម្មវិធីនេះបានជួយឧបត្ថម្ភដោយនាយកដ្ឋានជំនួយអន្តរៈកាលនៃរដ្ឋ ម៉ាស្សាឈូសេត្ស ។

***កម្មវិធីអប់រំនិតិជន ឬមនុស្សពេញវ័យ*** : កម្មវិធីនេះបង្រៀនកុំព្យូទ័រ, អក្ខរៈភាព និង **GED** ដល់អ្នកចូលរួមក្នុងវគ្គសិក្សា ។ កម្មវិធីនេះមានការសហការណ៍យ៉ាងជិតស្និតជាមួយមណ្ឌលអប់រំនិតិជនក្រុងឡូវែល។

***កម្មវិធីជំនួយចូលសញ្ជាតិ*** : កម្មវិធីនេះជួយដល់អ្នកដែលមានបំណងចូលសញ្ជាតិដោយជួយរៀបចំ និងបំពេញបែបបទពាក្យសុំក៏ដូចជាកំណត់ឯកសារចាំបាច់នានាដែលតម្រូវឲ្យមានភ្ជាប់ជាមួយពាក្យសុំ ។ កម្មវិធីនេះក៏ជួយផងដែរដល់ការត្រៀមលក្ខណៈសំរាប់ធ្វើសម្ភាសចូលសញ្ជាតិ ។

***កម្មវិធីសំរាប់អ្នកមករកជំនួយផ្ទាល់ និងការផ្តល់ពត៌មានអំពីភ្នាក់ងារផ្តល់សេវាកម្មផ្សេងៗទៀត*** : បុគ្គលិកសមាគមខ្មែរជួយលោកអ្នកដែលដើរចូលមកសមាគមដើម្បីសុំឲ្យជួយលើបញ្ហាផ្សេងៗ ។ យើងក៏ជួយផ្តល់ពត៌មានជូនបងប្អូនអំពីភ្នាក់ងារផ្តល់សេវាកម្មឯកទេសផ្សេងៗទៀតផងដែរ ។

***កម្មវិធីជំនួយគ្រួសារអ្នកដែលត្រូវនិរទេស ឬត្រូវបញ្ជូនត្រឡប់ទៅស្រុកវិញ*** : ដោយរួមសហការណ៍ជាមួយមហាវិទ្យាល័យច្បាប់ BOSTON សមាគមខ្មែរនឹងជួយស្រង់ពត៌មានដើម្បីកំណត់រកនិរទេសជនណាដែលគំរោង RUBY SLIPPERS អាចជួយចាត់ចែងសំណុំក្តីរបស់គាត់ (និរទេសជន) និងក្រុមគ្រួសាររបស់គាត់បាន ។